# ៣-សេចក្តីប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៩៩

## សេចក្តីប្រកាសលេខ ០២ ប្រក.
## ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាព
## អនាធិបតេយ្យក្នុងវិស័យជលផល

***

ដោយពិនិត្យឃើញថា ទោះ មានព្រឹត្យច្បាប់លេខ ៣៣ក្រ.ច ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល លិខិតបទដ្ឋានជាច្រើនទៀត ដែលរាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់ តាមដំណាក់កាលនីមួយៗ សំដៅមានវិធានការទប់ស្កាត់បទល្មើសជលផលក៏ដោយ ក៏នៅតែមានជនល្មើសបាន និងកំពុងឆ្លៀត ឱកាសប្រព្រឹត្តបទល្មើសជលផល បង្កអោយមានការបំផ្លិចបំផ្លាញប្រភពធនធានជលផលកើនធ្ងន់ធ្ងរថែមទៀត ។ ជាក់ស្តែងក្នុងរយះពេលប៉ុន្មានឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា ភាពអនាធិបតេយ្យលើវិស័យជលផលកំពុងតែជំរាមកំហែងធួរ [illegible]ន្ត្រូវបំពារស្ត ហើយប្រសិនបើបទល្មើសទាំងនេះនៅតែបន្តទៀតនោះ ប្រទេសកម្ពុជា នឹងឈានទៅបាត់បង់ទាំងបរិមាណ និងប្រភេទពូជត្រី នៅពេលអនាគតខាងមុខ ។

ស្ថិតនៅចំពោះមុខស្ថានភាពខាងលើ រាជរដ្ឋាភិបាលសំរេចកំណត់នូវវិធានការយ៉ាងម៉ឺងម៉ាត់ និងជាបន្ទាន់ដូចខាងក្រោម ៖

១-អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ និងសមត្ថកិច្ចពាក់ព័ន្ធ ត្រូវសហការជាមួយសមត្ថកិច្ចជលផលជាបន្ទាន់ បញ្ឈប់នូវការយកដែននេសាទដែលត្រូវការពារ និងកន្លែងនេសាទដែលទុកសំរាប់តែប្រជារាស្ត្រធ្វើអាជីវកម្មនេសាទ សិប្បកម្ម ឬ គ្រួសារទៅលក់អោយឯកជនដោយខុសច្បាប់ ។

២-ត្រូវបញ្ឈប់ការរាំងទឹកនៅក្នុងដែននេសាទដែលត្រូវការពារ និងក្នុងកន្លែងនេសាទបំរុងទុកនៅបឹងទន្លេសាប និងការធ្វើនេសាទដោយប្រើឧបករណ៍ហាមឃាត់ ជាពិសេសការប្រើជាតិផ្ទុះ ខ្សែភ្លើងឆក់ ការដាក់សំរាស់ ការដាក់កង់ឡាន ឬការធ្វើនេសាទដោយឧបករណ៍នេសាទដែលរុញ ឬអូសដោយកម្លាំងម៉ាស៊ីនជាដើមនៅទឹកសាប ។ ត្រូវហាមឃាត់ដាច់ខាតការផលិត ការលក់ ឬការដឹកជញ្ជូនឧបករណ៍នេសាទហាមឃាត់ ។

៣-ត្រូវបញ្ឈប់ការលើកទំនប់ ការកាប់រានព្រៃលិចទឹក ការផ្តល់លិខិតសំគាល់សិទ្ធិគ្រប់ប្រភេទលើដីធ្លី ក្នុងដែននេសាទ ដោយគ្មានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៤-ត្រូវបញ្ឈប់ការនេសាទដោយខុសច្បាប់នៅក្នុងរដូវបិទនេសាទ ។

ត្រូវហាមឃាត់ការចាប់កូនត្រី និងជាពិសេសការនាំកូនត្រីចេញទៅបរទេស ។

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង ″អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា″ ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

៥-ត្រូវបញ្ឈប់ការលើកលែងអោយទូកនេសាទបរទេសធ្វើអាជីវកម្មនេសាទ និងត្រូវបញ្ឈប់សកម្មភាពនេសាទល្មើសច្បាប់ នៅក្នុងដែនសមុទ្រកម្ពុជា ។

៦-ជនល្មើស និងអ្នកឃុបឃិត ឬអ្នកនៅពីក្រោយខ្នងការពារជនល្មើសក្នុងចំណុច ១.២.៣.៤.៥ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមានដ៏តឹងរឹងបំផុត ។ ឧបករណ៍ សំភារៈ និងមធ្យោបាយផ្សេងៗ ដែលធ្វើនេសាទល្មើសច្បាប់ត្រូវហូតទុក និងបញ្ជូនទៅតុលាការ ។

៧-ការត្រួតពិនិត្យ ការស្រាវជ្រាវរកបទល្មើសជលផល ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចជលផល ។ អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ត្រូវជួយផ្តល់កម្លាំងក្នុងការត្រួតពិនិត្យបទល្មើសជលផល ក្នុងករណីដែលមានការស្នើសុំពីសមត្ថកិច្ចជលផល ។

៨-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ត្រូវពិភាក្សាអំពីឡូត៍នេសាទ ដែលត្រូវរក្សាទុក និងឡូត៍នេសាទដែលត្រូវលុបចេញ ។

៩-សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់ ត្រូវចាត់វិធានការម៉ឺងម៉ាត់ និងសមស្របចំពោះកងកម្លាំងប្រដាប់អាវុធទាំងអស់ ដែលពាក់ព័ន្ធនឹងចំណុចបទល្មើសនេសាទទឹកសាប និងសមុទ្រជាបន្ទាន់ និងត្រូវបង្កលក្ខណៈងាយស្រួលដល់សមត្ថកិច្ចជលផលក្នុងការបំពេញភារកិច្ច ។

១០-មន្ត្រីរាជការជលផល សមត្ថកិច្ចផ្សេងៗ និងជនដែលមានស្នាដៃក្នុងការចូលរួមបង្ក្រាបបទល្មើសជលផល ត្រូវបានផ្តល់រង្វាន់លើកទឹកចិត្ត ដែលបានមកពីការផាកពិន័យ ដូចសមត្ថកិច្ច រុក្ខាប្រមាញ់ និងសមត្ថកិច្ចគយដែរ ។

១១-ជនណាអនុវត្តផ្ទុយពីសេចក្តីប្រកាសនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។ ទទួលបានសេចក្តីប្រកាសនេះគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់ ត្រូវខិតខំអនុវត្តវិធានការខាងលើនេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់ អោយមានប្រសិទ្ធភាព ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង ″អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា″ ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)